**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**ខុមហ្វ្រែល COMFREL**

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

1. លោក **ធន សារាយ** Mr. THUN Saray ប្រធានគណៈកម្មាធិការនាយក និងជាប្រធាន ADHOC
2. លោក **សុក សំអឿន** Mr. SOK Sam Oeun អនុប្រធានគណៈកម្មាធិការនាយក និងជានាយក CDP
3. លោក **យឹម ប៉ូ** Mr. YIM Po អគ្គលេខាធិការ និងជានាយក CCPCR
4. អ្នកស្រី **ស៊ុន ចាន់សែន** Mrs. SUN Chansen សមាជិកា និងជាប្រធាន KYA
5. លោក **យង់ គិមអេង** Mr. YONG Kim Eng សមាជិក និងជានាយក PDP-Center
6. លោក **មុំ សារិន** Mr. MOM Sarin សមាជិកា និងជានាយក HRCDO
7. អ្នកស្រី **ទីវ សារាយេត** Ms. TIV Sarayet សមាជិកា និងជាសហនាយិកា WMC
8. កញ្ញា **សយ សារា វឌ្ឍនី** Miss. SAY Sara Vathany សមាជិកា និងជានាយិកា CWCC
9. លោក **គីម សុវណ្ណ** Mr. KIM Sovann សមាជិក និងជានាយក VIGILANCE
10. នាយក LAC (NA)
11. នាយក KKKHRO (NA)
12. អ្នកស្រី **ពឹង យក់ហៀប** Ms. PEUNG Yok Hiep សមាជិកា ជាឥស្សរជន Dignitary
13. លោក **សឺន សែត** Mr. SEN Set សមាជិក ជាឥស្សរជន Dignitary

ស.ប្រ.ក.៣/លេខ ០៤/១០ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ក្នុងខេត្ត កំពង់ស្ពឺ

*ភ្នំពេញ, ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១០*

ម្ចាស់ឆ្នោតនៅខេត្តកំពង់ស្ពឺប្រមាណ ៨៥នាក់ ក្នុងនោះមានស្ត្រី ៣១នាក់ (៣៦%) មកពីសហគមន៍ព្រៃឈើ ដីធ្លី,,,,,,, អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ ដែលមកពីស្រុកផ្សេងគ្នាក្នុងខេត្តកំពង់ស្ពឺ បានបង្ហាញការពេញចិត្តទៅលើការបំពេញការងារមន្ត្រីជាប់ឆ្នោតក្នុងការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ស្ពឺ បើទោះបីជាលក្ខខណ្ឌសន្ទស្សន៍ទាំងនេះមិនត្រូវបានអនុវត្តបាន១០០% ក៏ដោយ។

ម្ចាស់ឆ្នោតភាគច្រើនបានធ្វើការវាយតម្លៃដោយផ្តល់ជាពិន្ទុការអនុវត្តន៍ លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនីមួយៗនៅចន្លោះធ្វើបានខ្លះ និងធ្វើបានពាក់កណ្តាល ក្នុងនោះចំនុចពីរដែលម្ចាស់ឆ្នោតមិនទាន់ពេញចិត្តការអនុវត្តន៍ដូចជាចំនុចទាក់ទងការផ្តល់ និងដោះស្រាយដីសម្បទានសង្គមកិច្ច ការរកទីផ្សា និងសំរបសំរួលតំលៃសំរាប់ផលិតផលកសិកម្ម និងការផ្តល់ការព្យាបាលដោយឥតគិតថ្លៃដល់អ្នកក្រ។

លើកលែងតែចំណុចទី៩ ស្នើអោយមានច្បាប់ប្រឆាំងអំពើពុករលួយ ដែលម្ចាស់ឆ្នោតភាគច្រើនវាយតម្លៃពេញចិត្តទាំងស្រុង ពី ៨១% ទៅ ១០០%។

ទោះបីយ៉ាងណា មន្ត្រីជាប់ឆ្នោត រួមមាន អ្នកតំណាងរាស្ត្រ ឯកឧត្តម **លី សុន** ឯកឧត្តម **នុត រំដួល**, សមាជិកក្រុមប្រឹក្សាខេត្ត ឯកឧត្តម **ពយ សារិទ្ធ** និងអភិបាលរងខេត្តកំពង់ស្ពឺ លោកស្រី **ទឹម សាវ៉ាត** បានសន្យាថា នឹងខិតខំប្រឹងប្រែងជម្រុញការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍ដែលមិនទាន់បានសម្រេច។

ការវាយតម្លៃនេះ ម្ចាស់ឆ្នោតធ្វើការផ្តល់ពិន្ទុទៅលើការបំពេញ/សម្រេចបានទៅលើចំនុចនីមួយៗដែលម្ចាស់ឆ្នោតបានធ្វើការទាមទារកាលពីឆ្នាំ២០០៩ ដោយឱ្យពិន្ទុ "ពិន្ទុ១ សំរាប់ការមិនបានធ្វើទាល់តែសោះ ឬបានធ្វើតិចតួច (ច្រើនបំផុតត្រឹម ២០%)" "ពិន្ទុ២ សំរាប់ការបានធ្វើខ្លះ (២១%-៤០%)" "ពិន្ទុ៣ សំរាប់ការបានធ្វើមធ្យម ឬបានធ្វើពាក់កណ្តាល (៤១%-៦០%)" "ពិន្ទុ៤ សំរាប់ការបានធ្វើច្រើន (៦១%-៨០%)" និង "ពិន្ទុ៥ សំរាប់ការបានធ្វើស្ទើរតែទាំងស្រុង ឬបានធ្វើទាំងស្រុង (៨១%-១០០%)"។

ជាលទ្ធផល ម្ចាស់ឆ្នោតបានផ្តល់ពិន្ទុទៅលើការសម្រេចបានរបស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗ ដែលម្ចាស់ឆ្នោតបានកំណត់កាលពីឆ្នាំ ២០០៩ ដូចខាងក្រោម៖

| **លទ្ធផលនៃការវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការសម្រេចបាន របស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗនៃ<br>លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអភិបាលកិច្ចនៅក្នុងខេត្តកំពង់ស្ពឺ** |
| --- |
| ១) សូមជួយទប់ស្កាត់ បង្ការការកាប់បំផ្លាញព្រៃឈើនៅស្រុក គងពិសី ឱរ៉ាល់ ភ្នំស្រួច ថ្ពង [ឱ្យបាន ១០០%] ចាប់ពីត្រឹមឆ្នាំ ២០០ និង សុំបង្កើតព្រៃសហគមន៍នៅតំបន់ភ្នំព្រះ ឃុំ យាអង្គ ស្រុកថ្ពង ចំនួន ៣.៨៧៩ ហិកតា នៅឆ្នាំ ២០០៩ និងសុំអោយរដ្ឋបាលព្រៃឈើជួយ រៀបចំសំណុំឯកសារ និងទទួលស្គាល់សហគមន៍ព្រៃឈើនៅឃុំ ទ័ពមាន ស្រុកថ្ពង។<br>ពិន្ទុ **១ (១៣%)** ពិន្ទុ **២ (៣៤%)** ពិន្ទុ **៣ (៤៥%)** ពិន្ទុ **៤(៦%)** ពិន្ទុ **៥ (១%)** |
| ២) សុំជួយដោះស្រាយដីសម្បទានសង្គមកិច្ចនៅឃុំអមលាំង ៨ ភូមិ ១.៨៥០ហិកតា នៅឃុំយាអង្គ ៣ភូមិ ១.៤០០ហិកតា នៅឃុំមហាសាំង និងតាំងស្យា នៅតំបន់ អា សេ អូ ផ្ទៃដីស្រែ ៤២៩,២៧ហិកតា ដីចំការ ១១៥,៤៧ហិកតា(១០សហគមន៍) និងសុំដោះស្រាយវិវាទដីនៅភូមិព្រីង ឃុំ រលាំងចក ស្រុកសំរោងទង។ សុំផ្តល់ប្លង់កម្មសិទ្ធដីនៅឃុំតាសាល់ ស្រុកឱរ៉ាល់។<br>ពិន្ទុ **១ (៣២%)** ពិន្ទុ **២ (៤០%)** ពិន្ទុ **៣ (២៦%)** ពិន្ទុ **៤ (៣%)** ពិន្ទុ **៥ (០%)** |
| ៣) ផ្តល់ថ្នាំវ៉ាក់សាំង បង្ការជំងឺសត្វអោយបានគ្រប់គ្រាន់មួយឆ្នាំម្តង (ឬតាមជំនាញបច្ចេកទេស) និងគ្រប់តំបន់ និងសូមត្រួតពិនិត្យទីសត្តឃាតជារៀងរាល់ថ្ងៃអោយបានដិតដល់ចាប់ពីខែ មេសា ឆ្នាំ ២០០៩ តទៅ។<br>ពិន្ទុ **១ (៣%)** ពិន្ទុ **២ (២៥%)** ពិន្ទុ **៣ (៤៨%)** ពិន្ទុ **៤ (២០%)** ពិន្ទុ **៥ (៤%)** |
| ៤) លុបបំបាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ (ប្រដាប់ឆក់ត្រី) អោយមានប្រសិទ្ធភាពមួយរយភាគរយនៅក្នុងឆ្នាំ ២០១០ និងលុបបំបាត់ការប្រមាញ់ និងបំពុលសត្វព្រៃអោយបានមួយរយភាគរយ ចាប់ពីឆ្នាំ ២០១០។<br>ពិន្ទុ **១ (១៣%)** ពិន្ទុ **២ (២៧%)** ពិន្ទុ **៣ (២៨%)** ពិន្ទុ **៤ (៣០%)** ពិន្ទុ **៥ (៣%)** |
| ៥) ប្រមូលសំរាមក្នុងផ្សារកំពង់ស្ពឺ និងក្នុងទឹកស្ទឹងឱ្យស្អាត និងសណ្តាប់ធ្នាប់នៅក្នុងផ្សារឱ្យហើយ ឆ្នាំ ២០០៩តទៅ។<br>ពិន្ទុ **១ (៦%)** ពិន្ទុ **២ (៨%)** ពិន្ទុ **៣ (៥១%)** ពិន្ទុ **៤ (៣៣%)** ពិន្ទុ **៥ (១%)** |
| ៦) សុំឱ្យរដ្ឋជួយទិញកសិផលនៅពេលគ្មានទីផ្សារសម្រាប់ផលិតផលកសិកម្ម ឬពេលដែលតម្លៃកសិផលធ្លាក់ចុះ ដោយរដ្ឋត្រូវឱ្យតម្លៃថ្លៃជាងទីផ្សារ។<br>ពិន្ទុ **១ (៣៧%)** ពិន្ទុ **២ (២៩%)** ពិន្ទុ **៣ (២៦%)** ពិន្ទុ **៤ (៨%)** ពិន្ទុ **៥ (០%)** |
| ៧) តម្លើងប្រាក់បៀវត្សរដល់មន្ត្រីរាជការ ជាពិសេសគ្រូបង្រៀន និងគ្រូពេទ្យពី ១០០ ដុល្លារ ឡើងទៅ ចាប់ពីឆ្នាំ ២០១០ និងផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូតាមកំរិត និងមុខជំនាញម្នាក់ៗឱ្យបានម្តងក្នុងមួយឆ្នាំនៅគ្រប់ភូមិសិក្សា ចាប់ពីឆ្នាំ ២០១០។<br>ពិន្ទុ **១ (៦%)** ពិន្ទុ **២ (៣៨%)** ពិន្ទុ **៣ (៤៣%)** ពិន្ទុ **៤ (១៣%)** ពិន្ទុ **៥ (០%)** |
| ៨) នៅគ្រប់មណ្ឌលសុខភាពត្រូវមានថ្នាំគ្រប់គ្រាន់ និងមានបុគ្គលិកជំនាញប្រចាំការគ្រប់ម៉ោងចាប់ពីចុងឆ្នាំ ២០០៩ និងបង្កើនការព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ។<br>ពិន្ទុ **១ (៨%)** ពិន្ទុ **២ (៤៨%)** ពិន្ទុ **៣ (៣៤%)** ពិន្ទុ **៤ (៩%)** ពិន្ទុ **៥ (៣%)** |

| |
|---|
| ៩) សុំឱ្យច្បាប់ប្រឆាំងអំពើពុករលួយចេញឱ្យបានឆាប់យ៉ាងយូរដើមឆ្នាំ ២០១០។<br>ពិន្ទុ **១ (៦%)** ពិន្ទុ **២ (១៤%)** ពិន្ទុ **៣ (១៤%)** ពិន្ទុ **៤ (១៩%)** ពិន្ទុ **៥ (៤៨%)** |
| ១០) សុំឱ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់ពីមូលដ្ឋាន រហូតដល់ថ្នាក់ខេត្តសុំឱ្យដោះស្រាយទំនាស់ដីធ្លីចាប់ពីខែមេសា ឆ្នាំ២០០៩ ជាពិសេសដី អា សេ អូ ដោះស្រាយឱ្យចប់នៅក្នុងឆ្នាំ ២០០៩ និងសុំឱ្យមានច្បាប់ផ្តន្ទាទោសដល់តុលាការ មន្ត្រីរាជការ យោធា ប៉ូលីស ប៉េអឹម នៅទូទាំងខេត្តកំពង់ស្ពឺ ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ និងប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូក ពីជនល្មើស ។<br>ពិន្ទុ **១ (២១%)** ពិន្ទុ **២ (៤២%)** ពិន្ទុ **៣ (២៥%)** ពិន្ទុ **៤ (៧%)** ពិន្ទុ **៥ (៥%)** |
| ១១) **ចំនុចរួមៈ តើអ្នកពេញចិត្តការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍ទាំង១០ កម្រិតណា?**<br>១) មិនពេញចិត្តទាល់តែសោះ, **(៣%)** ២) ពេញចិត្តតិចតួច, **(៨%)** ៣) ពេញចិត្តគួរសម, **(៣២%)** ៤) ពេញចិត្តច្រើន, **(៤១%)** ៥) ពេញចិត្តទាំងស្រុង **(១៧%)** |

ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយម្ចាស់ឆ្នោតក្នុងវេទិកាម្ចាស់ឆ្នោតដែលរៀបចំដោយគណៈកម្មាធិការ **ខុមហ្វ្រែល** ដោយមានកិច្ចសហការជាមួយសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), បណ្តាញអង្គការដើម្បីអភិវឌ្ឍន៍ និងតស៊ូមតិ (NDA), អង្គការដៃគូអភិវឌ្ឍន៍ (DKA) ។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ*

- លោក **សុខ ពិន្ទុរឿ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទៈ ០៨៩ ៥២៥ ៤៤៦